ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៧...០២០...៣៣៨...ស.ជ.ណ

ថ្ងៃ ពុធ ៥កើត ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែតុលា ឆ្នាំ២០២០

# សេចក្ដីជូនដំណឹង
## ចំពោះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ

ធនាគារជាតិនៃកម្ពុជា សូមថ្លែងសរសើរចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលបានចូលរួមសហការអនុវត្តយ៉ាងល្អ ក្នុងការអនុវត្តវិធានការនានារបស់រាជរដ្ឋាភិបាល និងធនាគារជាតិនៃកម្ពុជាដែលបានដាក់ចេញ ដូចជា សារាចរណែនាំស្ដីពីឥណទានរៀបចំឡើងវិញ ការអនុគ្រោះបន្ធូរ-បន្ថយកម្រៃសេវាផ្សេងៗពាក់ព័ន្ធនឹងឥណទាន និង/ឬលើកលែងការដាក់ពិន័យផ្សេងៗ និងការរឹបអូសទ្រព្យបញ្ចាំដោយមិនមានដីកាពីតុលាការ ជាដើម ក្នុងកំឡុងពេលនៃការរីករាលដាលនៃជំងឺកូវីដ១៩ ដើម្បីសម្រាលបន្ទុករបស់អ្នកខ្ចីប្រាក់ ។

ទន្ទឹមនេះ ក្នុងស្ថានភាពដែលខេត្ត-ក្រុងមួយចំនួននៃប្រទេសកម្ពុជាទទួលរងផលប៉ះពាល់ពីគ្រោះទឹកជំនន់ ធនាគារជាតិនៃកម្ពុជា ក៏ស្នើសុំដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ បន្តកិច្ចសហការល្អក្នុងក្របខណ្ឌកិច្ចការពារអតិថិជន និងបន្តផ្ដល់ការអនុគ្រោះតាមលទ្ធភាពចំពោះអ្នកខ្ចីប្រាក់ដែលបានរងផលប៉ះពាល់ជាក់ស្ដែងដោយសារទឹកជំនន់។

ធនាគារជាតិនៃកម្ពុជា សង្ឃឹមយ៉ាងមុតមាំថា គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ នឹងបន្តចូលរួមសហការប្រកបដោយការយោគយល់ និងអធ្យាស្រ័យខ្ពស់ ស្របតាមស្ថានភាពជាក់ស្ដែងរបស់អតិថិជន។

ប្រអប់សំបុត្រលេខ ២៥, ផ្ទះលេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧